**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣២៥ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ៥៧១ ប្រក.កសក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីវិធានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

# សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាន និងនីតិវិធីសម្រាប់ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីជលផល។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅ៖

- ជំរុញការអនុវត្តបទបញ្ជាបច្ចេកទេសវារីវប្បកម្ម សម្រាប់ផលិតកម្មត្រីរ៉ស់ ត្រីឆ្តោ
- ផ្តល់សេវាបច្ចេកទេសចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោ និងទប់ស្កាត់ការរាលដាលជំងឺត្រី
- កំណត់លក្ខខណ្ឌបច្ចេកទេស ការប្រើប្រាស់ចំណី និងទប់ស្កាត់បទល្មើសជលផល
- ជំរុញកំណើនការងារ បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ចជាតិ
- ចូលរួមធានាសន្តិសុខ និងសុវត្ថិភាពស្បៀង
- ធានានិរន្តរភាពធនធានជលផល និងបរិស្ថាន។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើគ្រប់សកម្មភាពវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោ ដែលរួមមានការចិញ្ចឹម ការបង្កាត់ពូជ និងការថែបំប៉ន ជាលក្ខណៈពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោ ជាលក្ខណៈពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម ដែលចេញដោយរដ្ឋបាលជលផលមានសមត្ថកិច្ច។

រូបវន្តបុគ្គលឬនីតិបុគ្គលមានកាតព្វកិច្ច៖

- ចុះកិច្ចសន្យាស្តីពីការធ្វើវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោ ជាមួយរដ្ឋបាលជលផលមានសមត្ថកិច្ច
- ត្រូវមានសៀវភៅសម្រង់ស្ថិតិវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោ ដែលកំណត់ដោយរដ្ឋបាលជលផល
- ត្រូវគោរពតាមបទបញ្ជាបច្ចេកទេសវារីវប្បកម្ម គោលការណ៍អនុវត្តវារីវប្បកម្មល្អ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ត្រូវសហការជាមួយមន្ត្រីរដ្ឋបាលជលផលក្នុងការទទួលយកការណែនាំ និងសេវាបច្ចេកទេស។

**ប្រការ៥.-**

ក. រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោត្រូវស្នើសុំលិខិតអនុញ្ញាតពីរដ្ឋបាលជលផលថ្នាក់កណ្តាល ក្នុងទំហំវារីវប្បកម្មដូចខាងក្រោម៖

១. ស្រះដែលមានផ្ទៃក្រឡាសរុប លើសពីពីរពាន់ (២ ០០០) ម៉ែត្រក្រឡា។

២. ស៊ងដែលមានផ្ទៃក្រឡាសរុប លើសពីមួយពាន់ (១ ០០០) ម៉ែត្រក្រឡា។

៣. បែដែលមានផ្ទៃក្រឡាសរុប លើសពីមួយរយហាសិប (១៥០) ម៉ែត្រក្រឡា។

៤. ការចិញ្ចឹមលើសពីសាមសិបប្រាំពាន់ (៣៥ ០០០) ក្បាល ឡើងទៅ។

ខ. រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើវារីវប្បកម្មត្រីរ៉ស់ ត្រីឆ្តោត្រូវស្នើសុំលិខិតអនុញ្ញាតពីខណ្ឌរដ្ឋបាលជលផលសាមី ក្នុងទំហំវារីវប្បកម្មដូចខាងក្រោម៖

១. ស្រះដែលមានផ្ទៃក្រឡាសរុប លើសពីពីររយ (២០០) ម៉ែត្រក្រឡា ដល់ពីរពាន់ (២ ០០០) ម៉ែត្រក្រឡា។

២. ស៊ងដែលមានផ្ទៃក្រឡាសរុប លើសពីមួយរយ (១០០) ម៉ែត្រក្រឡា ដល់មួយពាន់ (១ ០០០) ម៉ែត្រក្រឡា។

៣. បែដែលមានផ្ទៃក្រឡាសរុប លើសពីដប់ប្រាំ (១៥) ម៉ែត្រក្រឡា ដល់មួយរយហាសិប (១៥០) ម៉ែត្រក្រឡា។

៤. ការចិញ្ចឹមលើសពីបីពាន់ប្រាំរយ (៣ ៥០០) ក្បាល ដល់សាមសិបប្រាំពាន់ (៣៥ ០០០) ក្បាល។

គ. ការធ្វើវារីវប្បកម្មត្រីរស់ ត្រីឆ្លោ ជាលក្ខណៈគ្រួសារដែលមានទំហំវារីវប្បកម្មតិចជាងចំណុច ខ នៃប្រការនេះ មិនតម្រូវឲ្យមានលិខិតអនុញ្ញាតឡើយ ប៉ុន្តែត្រូវចុះបញ្ជីវារីវប្បកម្មនៅរដ្ឋបាលជលផលមានសមត្ថកិច្ចនៅជិតបំផុត ហើយត្រូវមានសៀវភៅសម្រង់ស្ថិតិ និងអនុវត្តតាមបទបញ្ជាបច្ចេកទេសវារីវប្បកម្ម។

**ប្រការ៦.-**

ហាមឃាត់ ៖

១. ការចាប់កូនត្រីរស់និងត្រីឆ្លោពីធម្មជាតិមកចិញ្ចឹម។

២. ការប្រើប្រាស់កូនត្រីទឹកសាបដែលចាប់ពីក្នុងធម្មជាតិក្នុងរដូវបិទនេសាទ ឬកូនត្រីដែលបានមកពីការធ្វើនេសាទខុសច្បាប់ធ្វើជាចំណី។

**ប្រការ៧.-**

ការចិញ្ចឹមត្រីរស់ ដែលប្រើប្រាស់ចំណីសិប្បនិម្មិតត្រូវបានជំរុញ និងលើកទឹកចិត្ត។

**ប្រការ៨.-**

ជនណាប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ